# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០១៨/០៧ របក.អគគ**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ឧសភា ឆ្នាំ ២០០៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ ឧសភា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាម បេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

ក. <u>ការងាររដ្ឋបាល</u>

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងស្តង់ដាសម្រាប់តុលាការគំរូ នៅថ្ងៃ ព្រហស្បតិ៍ ទី១៧ ខែឧសភា ឆ្នាំ២០០៧

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំប្រព័ន្ធសូចនាករ សម្រាប់តាមដានការអនុវត្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៧

-លិខិតស្នើសុំរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាត់តាំងមន្ត្រីបច្ចេកទេសមួយរូប ដើម្បីចូលរួមជាសមាជិក ក្រុមការងារបច្ចេកទេសក្នុងគម្រោងពង្រីកបន្ថែមតុលាការគំរូនៅកម្ពុជា

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ក.ក.ច.ន.យ) នៅថ្ងៃ ពុធ ទី០៦ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង ៩.០០ ព្រឹកនៅទីស្តីការគណៈរដ្ឋមន្ត្រី

-លិខិតស្នើសុំជួយពិនិត្យកែសម្រួលសេចក្តីព្រាងរបាយការណ៍ស្តីពីកិច្ចប្រជុំរបស់អង្គភាពសម្របសម្រួល អចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៧

ខ. <u>ការងារកំណែទម្រង់</u>

-រៀបចំប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងស្តង់ដា (Standard) សម្រាប់ តុលាការគំរូ នៅថ្ងៃ ព្រហស្បតិ៍ ទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧

-រៀបចំប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំប្រព័ន្ធសូចនាករ សម្រាប់តាមដានការអនុវត្ត កំណែទម្រង់ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៧

គ. ផ្សេងៗ

២-សន្និដ្ឋាន

ក្នុងខែ ឧសភា ឆ្នាំ ២០០៧ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាពគ្រប់គ្រងគម្រោងជា អង្គភាពប្រតិបត្តិ បានខិតខំបំពេញការងារយ៉ាងសកម្មក្នុងការរៀបចំ មូលដ្ឋានសម្រាប់ដំណើរការការងាររបស់ Sub-Group/TWG ដើម្បីរុញច្រានការអនុវត្ត កម្មវិធី សកម្មភាព កំណែទម្រង់ច្បាប់ និងតុលាការអោយបាន ខ្លាំងក្លា និងបានរៀបចំប្រជុំ ដើម្បីពិនិត្យ ពិភាក្សា លើសេចក្តីព្រាងស្តង់ដា (Standard)សម្រាប់តុលាការគំរូ និងបានរៀបចំប្រជុំ ពិគ្រោះ យោបល់ស្តីពីការរៀបចំប្រព័ន្ធសូចនាករ សម្រាប់តាមដានការអនុវត្តកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ។

៣-ទិសដៅអនុវត្តក្នុងខែបន្ត

-គ្រោងរៀបចំប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែ ទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ នៅតាមបណ្តាខេត្តនានា

- បន្តធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាព និងបញ្ជីគម្រោង តាមរយៈអនុក្រុម (Sub-Group/TWG)

-រៀបចំកម្មវិធីបណ្តុះបណ្តាលមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង និងកម្មវិធីបណ្តុះបណ្តាល មន្ត្រីគោលតាម ក្រសួង ស្ថាប័នអនុវត្ត

-បន្តការពិភាក្សាជាមួយក្រសួងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធអំពីវិស័យយុត្តិធម៌ទាំងមូល។

*រាជធានី ភ្នំពេញ ថ្ងៃទី ខែ មិថុនា ឆ្នាំ ២០០៧*

**អ្នកធ្វើរបាយការណ៍**

ហ៊ឹង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង